ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :...០២១..សប្រក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ស្ថានភាពក្រោយបទឈប់បាញ់ គិតពីម៉ោង៦ព្រឹក ថ្ងៃទី១៥ ដល់ម៉ោង៦ព្រឹក ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិជ្រាបថា សកម្មភាពរំលោភបំពានរបស់ភាគីថៃ មកលើដែនអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា បណ្តាលឱ្យមានផលប៉ះពាល់ និងការខូចខាតក្នុងខេត្តចំនួន៧ រួមមាន ខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កោះកុង និងខេត្តសៀមរាប។ បើគិតពីម៉ោង៦ព្រឹក ថ្ងៃទី១៥ ដល់ម៉ោង៦ព្រឹក ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦នេះ បច្ចុប្បន្នភាពនៃស្ថានការណ៍រួម មានជាអាទិ៍៖

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** មានពលរដ្ឋភៀសសឹក៣.៦៣៣នាក់បន្ថែមទៀត បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ។ ដូច្នេះ ក្នុងចំណោមពលរដ្ឋភៀសសឹកសរុបជាង៦សែន៤ម៉ឺននាក់ មានប្រមាណជាង៥សែននាក់ បានវិលត្រឡប់ទៅលំនៅឋានវិញ។ ពលរដ្ឋភៀសសឹកបន្តស្នាក់នៅជំរំមានចំនួន១៤០.៦៩៣នាក់ ក្នុងនោះស្ត្រីមាន៧៣.៦១៦នាក់ និងកុមារ៤៦.១៨០នាក់។ ពលរដ្ឋភៀសសឹកខ្លះវិលដល់ភូមិករមែន ប៉ុន្តែត្រូវបង្ខំចិត្តស្នាក់នៅជំរំបណ្តោះអាសន្នជាថ្មីទៀត ដោយសារផ្ទះសំបែងបានខូចខាតខ្ទេចរាបដល់ដី និងពោរពេញដោយសំណល់យុទ្ធភណ្ឌមិនទាន់ផ្ទុះរបស់យោធាថៃ។

**២-ការបើកឡើងវិញ និងការបន្តបិទផ្អាកសេវាសាធារណៈជាមូលដ្ឋាន៖ ខេត្តឧត្តរមានជ័យ** មានសាលារៀន២៣៦ មន្ទីរពេទ្យ/មណ្ឌលសុខភាព៣៤ រដ្ឋបាលខេត្ត១ មន្ទីរអង្គភាពជុំវិញខេត្ត៣៣ រដ្ឋបាលស្រុក៥ អង្គភាពកងកម្លាំងមានសមត្ថកិច្ចថ្នាក់ក្រុង ស្រុក១០ រដ្ឋបាលឃុំសង្កាត់២៣ និងប៉ុស្តិ៍នគរបាលរដ្ឋបាល២៣ បានបើកដំណើរការឡើងវិញ ខណៈសាលារៀន២៤ មន្ទីរពេទ្យ/មណ្ឌលសុខភាព៧ រដ្ឋបាលនៅថ្នាក់ឃុំ-សង្កាត់១ និងប៉ុស្តិ៍នគរបាលរដ្ឋបាល១ បន្តបិទផ្អាក។ **ខេត្តបន្ទាយមានជ័យ** អង្គភាពផ្តល់សេវាសាធារណៈនៅថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ បានបើកដំណើរការឡើងវិញ ខណៈសាលារៀន៥ និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១ បន្តបិទផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន៣២ មន្ទីរពេទ្យ/មណ្ឌលសុខភាព១២ និងអង្គភាពផ្តល់សេវាសាធារណៈនៅថ្នាក់ស្រុក១ និងឃុំ-សង្កាត់៦ បានបើកដំណើរការឡើងវិញ ខណៈសាលារៀន២៩ (៧កន្លែងខូចខាត និង២២កំពុងសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ) និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤ នៅបន្តបិទផ្អាក។ **ក្នុងស្ថានភាពដែលទីតាំងផ្តល់សេវាសាធារណៈមួយចំនួនបន្តបិទផ្អាក អាជ្ញាធររដ្ឋបាលដែនដី និងមន្ត្រីពាក់ព័ន្ធ បានកំពុងខិតខំបំពេញតួនាទីប្រកបដោយភាពបត់បែនតាមកាលៈទេសៈ ដើម្បីផ្តល់សេវាជាមូលដ្ឋានជូនប្រជាពលរដ្ឋ រួមទាំងសេវានៅឃុំ-សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលជាដើម។**

**៣-ផលប៉ះពាល់ និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖ ពុំទាន់ទទួលបាន។** ដូច្នេះ បើគិតចាប់ពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥មក **ការខូចខាតទ្រព្យសម្បត្តិឯកជន** សរុប រួមមាន ផ្ទះ៤៣៥ខ្នង អគារស៊ីវិលឯកជន៧ អគារស្នាក់នៅ/សណ្ឋាគារ១០ ស្ថានីយប្រេង៣ ផ្សារឯកជន១ រថយន្ត៣៤គ្រឿង ម៉ូតូ៨គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ៣ អាងទឹកនិងប្រព័ន្ធទឹកស្អាត៦កន្លែង ជង្រុកស្រូវ១ និងសត្វពាហនៈ/សត្វព្រៃ២ក្បាល។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** សរុប រួមមាន សាលារៀន២៥ មន្ទីរពេទ្យ/មណ្ឌលសុខភាព៩ សំណង់អគារ៤២ វត្តអារាម១៧ សាលាធទាន១ រូបសំណាក១ រថយន្ត១គ្រឿង ប្រាសាទបុរាណ៤ ស្ពាន៥ ផ្សារ១ ផ្លូវ៣២ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១ទីតាំង និងបណ្តាញបញ្ជូនអគ្គិសនី៣កន្លែង ខណៈអាជ្ញាធរមូលដ្ឋានបន្តស្រង់ទិន្នន័យផលប៉ះពាល់បន្ថែម។

**៤-កិច្ចអន្តរាគមន៍រៀបចំផ្ទះសំបែង និងភូមិករពលរដ្ឋភៀសសឹក៖ ខេត្តព្រះវិហារ** អាជ្ញាធរដែនដី និងមន្ត្រីពាក់ព័ន្ធកំពុងចុះស្រង់ផលប៉ះពាល់ និងការខូចខាត ព្រមទាំងបន្តដឹកជញ្ជូនស្បៀង និងត្រៀមមធ្យោបាយដឹកជញ្ជូនពលរដ្ឋត្រឡប់មកកាន់លំនៅឋាន។ **ខេត្តឧត្តរមានជ័យ** មានភូមិចំនួន៨៤ពុំទាន់អាចឱ្យពលរដ្ឋចូលទៅរស់នៅបាន ដោយអាជ្ញាធរដែនដី និងមន្ត្រីពាក់ព័ន្ធកំពុងរៀបចំផ្ទះ និងភូមិករពលរដ្ឋ១៧២ភូមិ ព្រមទាំងបន្តរៀបចំទីតាំងផ្តល់សេវាសាធារណៈដែលបានបិទផ្អាកកន្លងមក ឱ្យដំណើរការឡើងវិញ។ ។ **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរដែនដី និងមន្ត្រីពាក់ព័ន្ធបានរៀបចំកន្លែងស្នាក់នៅបណ្ដោះអាសន្ន២ទីតាំង ជូនពលរដ្ឋដែលពុំទាន់អាចចូលរស់នៅក្នុងផ្ទះចំនួន២.៧៣៥គ្រួសារ។ **ខេត្តបាត់ដំបង** អាជ្ញាធរដែនដី និងមន្ត្រីពាក់ព័ន្ធបានកំពុងបន្តចុះត្រួតពិនិត្យ និងជួយឧបត្ថម្ភគាំទ្រពលរដ្ឋដែលរងផលប៉ះពាល់។ **ខេត្តពោធិ៍សាត់** អាជ្ញាធរខេត្តកំពុងជួយសម្របសម្រួល និងដោះស្រាយការលំបាកជូនពលរដ្ឋចំនួន៨៧គ្រួសារដែលពុំទាន់អាចវិលត្រឡប់ទៅលំនៅឋានវិញ។ ក្រៅពីនេះអាជ្ញាធរដែនដី និងមន្ត្រីពាក់ព័ន្ធគ្រប់មូលដ្ឋាន បានកំពុងបន្តសហការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់ និងគ្រោះថ្នាក់បណ្ដាលមកពីយុទ្ធភណ្ឌមិនទាន់ផ្ទុះ។

ជារួម មកដល់ពេលនេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** បាននិងកំពុងយកចិត្តទុកដាក់ និងតាមដានសភាពការណ៍វិវត្តន៍នៅសមរភូមិមុខជាប់ជាប្រចាំ និងប្រកៀកស្មាជាមួយកងយោធពលខេមរភូមិន្ទ ដើម្បីការពារអធិបតេយ្យ និងបូរណភាពទឹកដីស្របច្បាប់។ ជាមួយគ្នានេះ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន **ក្រសួង**បានកំពុងបន្តតាមដាន និងគាំទ្រដល់ការរៀបចំបើកដំណើរការឡើងវិញនូវការផ្តល់សេវាសាធារណៈនានានៅតំបន់ព្រំដែនកម្ពុជា-ថៃ ដូចជាសាលាក្រុង ស្រុក ឃុំ-សង្កាត់ អធិការដ្ឋាននគរបាលក្រុង ស្រុក ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព។ល។ ទន្ទឹមនេះ ក៏បានណែនាំដល់រដ្ឋបាលខេត្តបន្តផ្តល់ការជួយគាំទ្រចាំបាច់នានាជូនប្រជាពលរដ្ឋដែលវិលត្រឡប់ទៅកាន់លំនៅឋានវិញតាមស្ថានភាព និងតម្រូវការជាក់ស្តែង ជាពិសេសអ្នកដែលទទួលរងនូវការខូចខាតផ្ទះសំបែង និងអ្នកមានជីវភាពខ្វះខាត ព្រមទាំងចុះសួរសុខទុក្ខ និងក្តាប់សភាពការណ៍ផ្សេងៗនៅមូលដ្ឋាន។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** គាំទ្រពេញទំហឹង ការបញ្ជាក់ច្បាស់ៗរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ថា **កម្ពុជានឹងមិនធ្វើសម្បទាននូវអធិបតេយ្យ ឬសេចក្តីថ្លៃថ្នូររបស់ខ្លួនឡើយ**។ ជាក់ស្តែងនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៦ ភាគីកម្ពុជាបានស្នើជាថ្មីឱ្យភាគីថៃ ចាត់បញ្ជូនក្រុមវាស់វែងចម្រុះ (Joint Survey Teams) ចុះលើដីជាក់ស្តែងឡើងវិញ ដើម្បីអនុវត្តការងារបោះបង្គោលបណ្តោះអាសន្ននៅកំណាត់ខ្សែព្រំដែនចន្លោះបង្គោលលេខ 42-47 និងបង្គោលលេខ 52-59 និងសាងសង់ឡើងវិញនូវបង្គោលព្រំដែនចំនួន១៥ តាមគំរូដើមបង្គោលជំនាន់បារាំង នៅទីតាំងដើមពិតប្រាកដែលភាគីទាំងពីរបានឯកភាពគ្នា។ យើងជឿជាក់ថា ភាគីថៃនឹងឆ្លើយតបជាវិជ្ជមានប្រកបដោយភាពប្រាកដនិយម និងស្មោះត្រង់ ស្របតាមជំហររបស់នាយករដ្ឋមន្ត្រីថៃ **ឯកឧត្តម** Anutin Charnvirakul បានថ្លែង និងចុះផ្សាយតាមកាសែត The Nation Thailand ថា **ក្រុមការងារកម្រិតបច្ចេកទេស (វាស់វែងចម្រុះ-Joint Survey Teams) នៅបន្តអនុវត្តការងាររបស់ខ្លួនដដែល**។

ជាថ្មីម្តងទៀត **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគោរពស្ញប់ស្ញែងចំពោះសារប្រកបដោយភាពម៉ឺងម៉ាត់ប្រាកដនិយមដែល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃកម្ពុជា ផ្ញើជូនជនរួមជាតិ កាលពីយប់ថ្ងៃទី១៣ ខែមករាថា **គន្លឹះសំខាន់របស់ជាតិយើងនាពេលនេះ គឺយើងត្រូវប្រែក្លាយការលំបាករបស់ជាតិ និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់ខ្មែរគ្រប់រូបនាពេលនេះ ឱ្យក្លាយទៅជាកម្លាំងតស៊ូដ៏រឹងមាំរបស់ជាតិ និងគោលដៅដ៏ពិសិដ្ឋរបស់ជាតិ ពោលគឺការរួមសាមគ្គីភាពគ្នាជាធ្លុងមួយ ដើម្បីការពារជាតិមាតុភូមិជាទីស្រឡាញ់របស់យើង និងធ្វើឱ្យជាតិខ្មែរយើងបានរឹងមាំ ស្របតាមបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ខ្មែរគ្រប់រូប។ ជាមួយគ្នានេះ និងចំពោះមុខនេះ យើងមានភាពចាំបាច់ ក្នុងការរួបរួមសាមគ្គីគ្នាជាធ្លុងមួយជាមួយនឹងការប្តេជ្ញាចិត្តរួមរបស់ជាតិ ដើម្បីពង្រឹងសក្តានុពលជាតិលើគ្រប់វិស័យ និងលុបបំបាត់ភាពអសកម្មទាំងឡាយក្នុងសង្គមជាតិ ដែលធ្វើឱ្យជាតិចុះខ្សោយ**។

ក្នុងនាមសេនាធិការរាជរដ្ឋាភិបាលលើការងារអនុវត្តច្បាប់ និងគ្រប់គ្រងរដ្ឋបាលដែនដី **ក្រសួងមហាផ្ទៃ** សូមអំពាវនាវជនរួមជាតិ មន្ត្រីរាជការ អាជ្ញាធរមូលដ្ឋាន កងកម្លាំងមានសមត្ថកិច្ច ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូជាតិនានា រួបរួមជាធ្លុងមួយក្នុងស្មារតីព្រលឹងខ្មែរតែមួយជានិរន្តន៍ជៀសទៅ។

ថ្ងៃសុក្រ ១៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦